**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Aug-2013, 09:18
CMS/CFO: Phok Chanthan

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស បកប្រែ ខ្មែរ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៣

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ សាធារណៈ

ឋានៈនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើរបស់សហមេធាវីនាំមុខស្នើសុំកោះហៅដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះកែសម្រួលរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដើម្បីផ្តល់សក្ខីកម្មក្នុងអំឡុងសវនាការស្តីពីផលប៉ះពាល់ (ភ្ជាប់មកជាមួយឧបសម្ព័ន្ធសម្ងាត់)**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

គង់ ពិសី

យុង ផានិត

សំ សុគង់

វ៉េន ពៅ

ទី ស្រីនណា

គង់ ផល្លៈ

Emmanuel ALTIT

Pascal AUBOIN

Olivier BAHOUGNE

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Andrew T. CAYLEY

យ៉េត ចរិយា

William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន

អៀង សារី

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Patrick BAUDOIN

Evelyne BOILEAU-BRANDOMIR

Philippe CANONNE

Annie DELAHAIE

Laure DESFORGES

Ferdinand DJAMMEN NZEPA

Elodie DULAC

Nicole DUMAS

Isabelle DURAND

Françoise GAUTRY

Marie GUIRAUD

Emmanuel JACOMY

Martine JACQUIN

Daniel LOSQ

Christine MARTINEAU

Mahdev MOHAN

Barnabé NEKUIE

Lyma NGUYEN

Elisabeth RABESANDRATANA

Julien RIVET

Fabienne TRUSSES NAPROUS

Nushin SARKARATI

Jeanne SULZER

Philippine SUTZ

Beini YE

Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

Jacques VERGES

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

Original EN: 00906709-00906712

## I. សេចក្តីផ្តើម

១. ដើមបណ្តឹងរដ្ឋប្បវេណីបានទទួល និងបានធ្វើការពិចារណាយ៉ាងយកចិត្តទុកដាក់ទៅលើសារអេឡិចត្រូនិករបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ ពាក់ព័ន្ធនឹងសវនាការដែលត្រូវបានរំពឹងទុកស្តីពីផលប៉ះពាល់/ការឈឺចាប់[1]។ លើសពីនេះទៀត ថ្មីៗនេះ ពួកគាត់បានទទួលដំណឹងពី Wendy Lobwein ប្រធានផ្នែកគាំពារសាក្សី និងអ្នកជំនាញ ថាសវនាការទាំងនេះត្រូវបានគ្រោងធ្វើនៅថ្ងៃទី ២៧, ២៩ និង ៣០ ខែ ឧសភា និងថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៣។

២. ដើម្បីជំរុញការរៀបចំផែនការសម្រាប់សវនាការស្តីពីផលប៉ះពាល់/ការឈឺចាប់ ដើមបណ្តឹងរដ្ឋប្បវេណីបានកែសម្រួលបញ្ជីឈ្មោះដើមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់ពួកគាត់ ដែលត្រូវផ្តល់សក្ខីកម្មស្តីពីផលប៉ះពាល់[2] ដើម្បីទទួលបានបញ្ជីឈ្មោះស្ថាពរស្តីពីបុគ្គលនានាដែលពួកគាត់មានបំណងស្តាប់សក្ខីកម្ម។ ជាងនេះទៀត ពួកគាត់បានរៀបចំសំណើកាលបរិច្ឆេទសម្រាប់សវនាការរយៈពេល ៤ ថ្ងៃនេះ ដែលសេចក្តីលម្អិតនៃចំណុចនេះមាននៅក្នុងឧបសម្ព័ន្ធ ១ នៃសំណើនេះ ដែលមានចំណងជើងថា សំណើកាលបរិច្ឆេទរបស់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការស្តីពីផលប៉ះពាល់របស់ជនរងគ្រោះ (“សំណើកាលបរិច្ឆេទ”)។

## II. ការពិភាក្សា

៣. ដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ជាក់ថា ពួកគាត់បានកាត់បន្ថយចំនួនបុគ្គលដែលត្រូវបានស្នើសុំឱ្យស្តាប់សក្ខីកម្មពី ២២ រូប (ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២០ រូប និងអ្នកជំនាញចំនួន ២ រូប) មកនៅត្រឹម ១៤ រូប (ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៣ រូប និងអ្នកជំនាញចំនួន ១ រូប)។ បន្ថែមពីលើបុគ្គលចំនួន

[1] សារអេឡិចត្រូនិកពី Susan Lamb, មន្ត្រីច្បាប់ជាន់ខ្ពស់ ទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី “ដើមបណ្តឹងរដ្ឋប្បវេណី និងបុគ្គលផ្សេងៗ ដែលត្រូវបានស្នើសុំស្តាប់សក្ខីកម្មស្តីពីទុក្ខវេទនា ក្នុងអំឡុងថ្ងៃសវនាការចំនួន ៤ ថ្ងៃ ដែលត្រូវបានផ្តល់សម្រាប់គោលបំណងនេះ” ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣។

[2] Liste des parties civiles proposes par les Co-avocats principaux pour étre entendues pendant les audiences relatives a líncidence des crimes allégués sur les victimes, comprenant l’Annexe Confidentielle 1, E236/5/3, ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៣។

Original EN: 00906709-00906712

១៤ រូបនេះ ដើមបណ្តឹងរដ្ឋប្បវេណីសូមកោះហៅដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣ រូបបន្ថែមទៀតដើម្បីត្រៀមបម្រុងសម្រាប់ការផ្តល់សក្ខីកម្ម ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីណាមួយក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានផ្តល់អាទិភាព ពុំមានលទ្ធភាពអាចផ្តល់សក្ខីកម្ម ឬប្រសិនបើការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីជាអាទិភាព បញ្ចប់ទៅនៅមុនកាលបរិច្ឆេទ។ ជាងនេះទៀត ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤ រូប ដែលត្រូវបានស្នើសុំឲ្យផ្តល់សក្ខីកម្ម និងរស់នៅក្រៅប្រទេសកម្ពុជា ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២ រូប បានស្នើសុំតាមរយៈមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់ ដើម្បីផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ជំនួសឲ្យការផ្តល់សក្ខីកម្មដោយផ្ទាល់តែម្តង។

៤. នៅក្នុងការរៀបចំសំណើកាលបរិច្ឆេទ ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើអ្វីដែលពួកគាត់ជឿថាជាការប៉ាន់ប្រមាណដ៏ប្រាកដនិយមមួយអំពីពេលវេលាសម្រាប់ការសួរដេញដោលសម្រាប់ថ្ងៃសវនាការមួយៗ (៥ ម៉ោង) និងដោយមានយកចិត្តទុកដាក់ជាពិសេសក្នុងការផ្តល់ឲ្យភាគីផ្សេងៗ (ដែលពួកគាត់យល់ថាត្រូវគិតរួមទាំងអង្គចៅក្រម/ចៅក្រម) នូវពេលវេលាគ្រប់គ្រាន់ និងប្រកបដោយសមមាត្រដើម្បីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ។ ជាងនេះទៀត ដើមបណ្តឹងរដ្ឋប្បវេណីបានរក្សាទុកពេលវេលាមួយចំនួនតូចសម្រាប់បញ្ហាបន្ទាន់នានាដែលពុំអាចដឹងមុន។

## IV. សំណើ

៥. អាស្រ័យដូចបានរៀបរាប់ខាងលើ ដើមបណ្តឹងរដ្ឋប្បវេណីសូមគោរពស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាឯកភាពលើសំណើកាលបរិច្ឆេទនេះ ព្រមទាំង៖

ក) បង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ចាប់ផ្តើមរៀបចំសម្រាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដោយអនុលោមតាមសំណើកាលបរិច្ឆេទនេះ រួមទាំងការផ្គត់ផ្គង់ថវិកាសម្រាប់ការធ្វើដំណើរ និងការចំណាយពាក់ព័ន្ធរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២ រូប ដែលបច្ចុប្បន្នរស់នៅក្រៅប្រទេស ហើយនឹងមកផ្តល់សក្ខីកម្មដោយផ្ទាល់នៅតុលាការ។

ខ) ជូនដំណឹងទៅភាគីផ្សេងៗទាំងអស់អំពីពេលវេលា ដែលត្រូវបានបែងចែករួមគ្នាទៅឲ្យពួកគាត់ ដើម្បីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ និង

គ) កោះហៅដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលមានឈ្មោះនៅក្នុងសំណើកាលបរិច្ឆេទ និងដោយអនុលោមតាមសំណើកាលបរិច្ឆេទនេះ។

សូមអង្គជំនុំជម្រះទទួលនូវក្តីគោរពអំពីយើងខ្ញុំ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៣ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Elisabeth SIMONNEAU-FORT<br>សហមេធាវីនាំមុខ | ភ្នំពេញ | |